ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករទូរគមនាគមន៍កម្ពុជា

លេខ :......១២២៨......ន.ទ.ក.

# សេចក្តីណែនាំ

# ស្តីពី

# ការពង្រឹងគុណភាព សោភ័ណភាពបណ្តាញខ្សែកាប្លិ៍ទូរគមនាគមន៍ខាងក្រៅគ្រប់ប្រភេទ នៅក្នុងទីប្រជុំជន រាជធានី ខេត្ត/ក្រុងនៃព្រះរាជាណាចក្រកម្ពុជា

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍ និងអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនិយ័តករទូរគមនាគមន៍កម្ពុជា និងសេចក្តីណែនាំជាបន្តបន្ទាប់របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងកិច្ចប្រជុំណែនាំនិយ័តកម្មទូរគមនាគមន៍ចាប់តាំងពីឆ្នាំ២០១១ តរៀងមក ស្តីពីការពង្រឹងគុណភាព សោភ័ណភាពបណ្តាញខ្សែកាប្លិ៍ទូរគមនាគមន៍ខាងក្រៅគ្រប់ប្រភេទ នៅក្នុងរាជធានីភ្នំពេញ ខេត្ត/ក្រុង និងទីប្រជុំជននៃព្រះរាជាណាចក្រកម្ពុជា និងរយៈពេលចុងក្រោយនេះ ការរីកចម្រើននៃហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ ពិតជាបានរួមចំណែកជំរុញឱ្យសេវាទូរ-គមនាគមន៍ (សេវាទូរស័ព្ទ និងសេវាអ៊ីនធឺណិត) មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់។ ទន្ទឹមនឹងនេះដែរ ការអភិវឌ្ឍនិងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍គ្រប់ប្រភេទ ជាពិសេសការរាយបណ្តាញខ្សែកាប្លិ៍ព្យួរខាងក្រៅ (ខ្សែកាប្លិ៍ទូរស័ព្ទ និងខ្សែកាប្លិ៍អុបទិក) របស់បណ្តាប្រតិបត្តិករទូរគមនាគមន៍ នៅពុំទាន់គោរពតាមស្តង់ដាបច្ចេកទេសទាំងស្រុង និងគ្មានរបៀបរៀបរយ កន្លែងខ្លះមានសភាពយើងឃោងដូចសំបុកពីងពាង ដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថានសង្គមសណ្តាប់ធ្នាប់សាធារណៈ និងបាត់បង់សោភ័ណភាពរាជធានី ខេត្ត/ក្រុង និងទីប្រជុំជនទូទាំងព្រះរាជាណាចក្រកម្ពុជា។

ដើម្បីឱ្យការអភិវឌ្ឍ និងការធ្វើអាជីវកម្មលើមូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ មានភាពរឹងមាំ ទំនើបកម្មលើគុណភាពសេវា សុវត្ថិភាពបណ្តាញ រួមចំណែករក្សាសោភ័ណភាពនិងបរិស្ថានសង្គម សណ្តាប់ធ្នាប់សាធារណៈ ចៀសវាងការបង្កគ្រោះថ្នាក់ផ្សេងៗដោយថាហេតុ ពិសេសតាមតំបន់ទីប្រជុំជន រាជធានី ខេត្ត/ក្រុង ទូទាំងព្រះរាជាណាចក្រកម្ពុជា និយ័តករទូរគមនាគមន៍កម្ពុជា សូមធ្វើការណែនាំដល់ លោក លោកស្រីប្រធានក្រុមហ៊ុន/ប្រតិបត្តិករផ្តល់បណ្តាញនិងសេវាទូរគមនាគមន៍គ្រប់ប្រភេទអនុវត្តឱ្យបានម៉ឺងម៉ាត់បំផុតដូចតទៅៈ

១) រាល់ការសាងសង់បណ្តាញខ្សែកាប្លិ៍ទូរគមនាគមន៍គ្រប់ប្រភេទ ត្រូវមកសុំការអនុញ្ញាតជាមុនដាច់ខាតពីនិយ័តករទូរគមនាគមន៍កម្ពុជា ស្របតាមមាត្រា ១៤ នៃច្បាប់ស្តីពីទូរគមនាគមន៍ និងសុំគោលការណ៍អនុញ្ញាតពីក្រសួងឬស្ថាប័នពាក់ព័ន្ធ ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន និងជូនដំណឹងដាច់ខាតជូនមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត ស្របតាមប្រកាសលេខ២៥០ បទ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់ព័ត៌មានអំពីការសាងសង់ ដំឡើងរុះរើ ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

២) បញ្ឈប់រាល់ការស្ថាបនាថ្មីនូវបណ្តាញខ្សែកាប្លិ៍ខាងក្រៅប្រភេទខ្សែអាកាស ព្យួរលើបង្គោលអគ្គិសនី ឬបង្គោលទូរស័ព្ទ ឬបង្គោលប្រហាក់ប្រហែល នៅក្នុងទីតាំងរាជធានីភ្នំពេញ ទីរួមខេត្ត ក្រុង និងទីប្រជុំជនសំខាន់ៗ ទូទាំងព្រះរាជា-ណាចក្រកម្ពុជា។ លើកលែងតែខ្សែកាប្លិ៍តភ្ជាប់ចូលទីតាំងអ្នកប្រើប្រាស់ (Last Mile Cable) ដែលអាចបំពាក់ខាងក្រៅដោយមានសណ្តាប់ធ្នាប់ តែមិនត្រូវរាយឆ្លងកាត់ទទឹងផ្លូវ និងឆ្លងកាត់បង្គោលលើសពីមួយឡើយ ។



(855) 23 72 23 33
(855) 23 72 32 22
info@trc.gov.kh
www.trc.gov.kh

៣) ហាមដាច់ខាតមិនឱ្យបំពាក់និងរាយបណ្តាញខ្សែកាប្លិ៍ទូរគមនាគមន៍អាកាសថ្មីគ្រប់ប្រភេទ ព្យួរលើបង្គោលអគ្គិសនី ឬបង្គោលទូរស័ព្ទ ឬបង្គោលប្រហាក់ប្រហែល នៅតាមបណ្តោយនិង/ឬឆ្លងកាត់មហាវិថី វិថី ផ្លូវនានា ដែលអាជ្ញាធររាជធានីភ្នំពេញ និងខេត្ត/ក្រុង បានធ្វើការសំអាតរួចរាល់ហើយនោះ។

៤) ដាច់ខាតត្រូវរៀបចំ និងបង្វែររាល់បណ្តាញខ្សែកាប្លិ៍អាកាសទូរគមនាគមន៍គ្រប់ប្រភេទ ដែលកំពុងបំពាក់និងរាយព្យួរលើបង្គោលអគ្គិសនី ឬបង្គោលទូរស័ព្ទ ឬបង្គោលប្រហាក់ប្រហែល នៅតាមបណ្តោយនិង/ឬឆ្លងកាត់មហាវិថី វិថី ផ្លូវនានានៅតាមរាជធានី ខេត្ត/ក្រុងទូទាំងព្រះរាជាណាចក្រកម្ពុជា មកបង្កប់ឬដាក់ក្នុងបំពង់ទូរគមនាគមន៍ក្រោមដី ដែលបានសាងសង់ដោយបណ្តាប្រតិបត្តិករមានអាជ្ញាបណ្ណប្រតិបត្តិការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ/បណ្តាញដូចជា៖ ទូរគមនាគមន៍កម្ពុជា និងក្រុមហ៊ុន Cambodia Fiber Optic Networks Co., Ltd. (CFOCN) ឬក្រុមហ៊ុននានាដែលមានប្រព័ន្ធបំពង់ក្រោមដីស្រាប់។ នៅក្នុងកាលៈទេសៈ និងទីតាំងពុំទាន់មានបណ្តាញបំពង់ទូរគមនាគមន៍ក្រោមដី បណ្តាក្រុមហ៊ុន/ប្រតិបត្តិករទូរគមនាគមន៍ ត្រូវរៀបចំសណ្តាប់ធ្នាប់ និងសុវត្ថិភាពបណ្តាញ ចំពោះខ្សែកាប្លិ៍អាកាសឆ្លងកាត់ផ្លូវត្រូវធានាកម្រិតកម្ពស់អនុញ្ញាត និងព្យួរស្លាកសម្គាល់កម្ពស់ជាក់ស្តែង និងខ្សែកាប្លិ៍អាកាសរត់ស្របផ្លូវត្រូវពិនិត្យថ្នក់ខ្សែឱ្យបានត្រឹមត្រូវស្របតាមលក្ខណៈបច្ចេកទេស បំពាក់ស្លាកសញ្ញាសម្គាល់កម្មសិទ្ធិខ្សែខ្លួន ដើម្បីជាប្រយោជន៍ងាយស្រួលថែទាំ និងគ្រប់គ្រង ។ រាល់ការដំឡើង ឬបំពាក់ទូរចែកចាយកាប្លិ៍ (Cabinet) ឬ ប្រអប់បែងចែកកាប្លិ៍ (Distribution Box-DP) នៅតាមចញ្ចើមផ្លូវ លើបង្គោល ឬជញ្ជាំងអាគារចាំបាច់ត្រូវមានភាពរឹងមាំ មិនបង្កឧបសគ្គ ឬគ្រោះថ្នាក់ជាយថាហេតុ ។

៥) ទូរគមនាគមន៍កម្ពុជា ក្រុមហ៊ុនកាំមីនតែល និងបណ្តាក្រុមហ៊ុន/ប្រតិបត្តិករផ្តល់បណ្តាញទូរគមនាគមន៍ ដែលបានសាងសង់ និងដាំបង្គោលទូរគមនាគមន៍ ដើម្បីបំពាក់បណ្តាញខ្សែកាប្លិ៍អាកាសទូរគមនាគមន៍ ត្រូវគោរពឱ្យបានពេញលេញតាមស្តង់ដាបច្ចេកទេសសាងសង់បណ្តាញទូរគមនាគមន៍ និងជួសជុល/ថែទាំជាប្រចាំបង្គោលទាំងនោះ មិនអនុញ្ញាតឱ្យទ្រេតឬដួលរលំដាច់ខាតចាប់ពីពេលនេះតទៅ។ ក្នុងករណីរកឃើញ មិនព្រមអនុវត្តឬផ្ទុយពីការណែនាំក្នុងវាក្យខណ្ឌទី១ នៃចំណុច៥នេះ និងបង្កឱ្យមានផលប៉ះពាល់ដល់សោភ័ណភាព បរិស្ថានសង្គមសណ្តាប់ធ្នាប់សាធារណៈ និងគ្រោះមហន្តរាយផ្សេងៗជាយថាហេតុ សហគ្រាស ឬក្រុមហ៊ុន/ប្រតិបត្តិករនោះត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់និងបទប្បញ្ញត្តិជាធរមាន។ ដូចគ្នាផងដែរ ការណែនាំនេះត្រូវអនុវត្តដូចគ្នានូវរាល់ការប្រព្រឹត្តទាំងឡាយនៃប្រតិបត្តិករណាមួយ ដែលបានលួចបំពាក់លើបង្គោលទាំងនោះ ដោយមិនមានការអនុញ្ញាតពីម្ចាស់បង្គោល។

និយ័តករទូរគមនាគមន៍កម្ពុជា មានជំនឿយ៉ាងមុតមាំចំពោះការចូលរួមអនុវត្តពីសំណាក់ក្រុមហ៊ុន/ប្រតិបត្តិករទូរគមនាគមន៍ទាំងអស់ ឱ្យមានប្រសិទ្ធភាពខ្ពស់នូវរាល់ខ្លឹមសារនៃសេចក្តីណែនាំនេះ រួមចំណែកធ្វើឱ្យកាន់តែប្រសើរឡើងនូវគុណភាពសេវា សុវត្ថិភាពបណ្តាញ និងលើកស្ទួយសោភ័ណភាពបរិស្ថានរាជធានីភ្នំពេញ ខេត្ត/ក្រុងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណី ក្រុមហ៊ុន/ប្រតិបត្តិករណាមួយមិនព្រមអនុវត្តតាមសេចក្តីណែនាំនេះ ក្រុមហ៊ុន/ប្រតិបត្តិករត្រូវទទួលខុសត្រូវចំពោះមុខច្បាប់និងបទប្បញ្ញត្តិជាធរមាន នៅពេលបង្កឱ្យមានការប៉ះពាល់ដល់សោភ័ណភាព បរិស្ថានសង្គម សណ្តាប់ធ្នាប់សាធារណៈ និងគ្រោះមហន្តរាយផ្សេងៗជាយថាហេតុ។

ថ្ងៃ អង្គារ ៨ កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០១៩

**ប្រធាន**

**ម៉ុង ចរិយា**

**ចម្លងជូន៖**

- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋបាលរាជធានីភ្នំពេញ
- រដ្ឋបាលខេត្ត/ក្រុង ទូទាំងព្រះរាជាណាចក្រកម្ពុជា
- អគ្គិសនីកម្ពុជា
- មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ខេត្ត
  "ដើម្បីជូនជ្រាប"
- គ្រប់ក្រុមហ៊ុន/ប្រតិបត្តិករទូរគមនាគមន៍ទាំងអស់
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ